# អង្គការ ទ្រទ្រង់ស្ត្រីខ្មែរ (COWS)

# Cambodian Organization for Women Support

## បទបង្ហាញសង្ខេប លទ្ធផលគម្រោងបានអនុវត្ត

កំពង់ធំ,ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

# មាតិកា

- ប្រវត្តិអង្គការ  និងព័ត៌មានទូទៅ
- សកម្មភាពតាមគម្រោង និងលទ្ធផលរីកចម្រើន
- បញ្ហាប្រឈម- ដំណោះស្រាយ
- ការសន្និដ្ឋាន

# ប្រវត្តិអង្គការទ្រទ្រង់ស្ត្រីខ្មែរ

- **អត្តសញ្ញាណរបស់អង្គការទ្រទ្រង់ស្ត្រីខ្មែរ:**

អង្គការទ្រទ្រង់ស្ត្រីខ្មែរ គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយឯករាជ្យ មិនរកប្រាក់ចំណេញ មិនធ្វើនយោបាយ ។ អង្គការ បានបង្កើតឡើងនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងបានច្បាប់អនុញ្ញាតពីក្រសួងមហាផ្ទៃ នៅថ្ងៃ១៧ ខែតុលា ឆ្នាំ២០០២។ អង្គការមានក្រុមប្រឹក្សាភិបាលចំនួន៣រូប/ស្រី១រូបនិង មានបុគ្គលិកចំនួន ៥រូប ស្រី ៣រូប ដើម្បីប្រតិបត្តិការងារអភិវឌ្ឍន៍សហគមន៍ នៅក្នុងខេត្តកំពង់ធំ និង តាមបណ្តាខេត្តមួយចំនួនដែលនៅជាប់ជាមួយខេត្តកំពង់ធំ (ខេត្តព្រះវិហារ ស្ទឹងត្រែង) ។

• អង្គការទ្រទ្រង់ស្ត្រីខ្មែរមានរចនាសម្ព័ន្ធច្បាស់លាស់គឺមានអ្នកគ្រប់គ្រង-ដឹកនាំកម្មវិធី និងមន្ត្រីគម្រោង ដោយមានការបែងចែកការងារដល់បុគ្គលិក តាមផ្នែក និងជំនាញ ដើម្បីទទួលខុសត្រូវ។អង្គការមានបុគ្គលិកប្រកបដោយសមត្ថភាព និងជំនាញដូចជាៈ ការរៀបចំចងក្រងសហគមន៍ ការកសាងសមត្ថភាពដល់តំណាងសហគមន៍ និង អ្នកជាប់ភារកិច្ច អំពីការពង្រឹងសិទ្ធិអំណាច និងគណនេយ្យភាពសង្គម បច្ចេកទេសកសិកម្មនិងជលផល សុខភាពនិងអនាម័យ យេនឌ័រ និង អភិបាលកិច្ចល្អ។សកម្មភាពដែលត្រូវអនុវត្ត គឺកាគាំទ្រដល់សហគមន៍និង ពង្រឹងសមត្ថភាព ដល់ប្រជាពលរដ្ឋ និង អ្នកជាប់ភារកិច្ច ពិសេស ស្ត្រីក្នុង ភាពជាអ្នកដឹកនាំស្ត្រី ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ក្នុងគោលបំណងចូលរួម ការងារអភិវឌ្ឍសហគមន៍និងសង្គម។

- **ទស្សនវិស័យ៖**

ប្រជាពលរដ្ឋកម្ពុជា ជាពិសេសស្ត្រីក្រីក្រ និងជនងាយរងគ្រោះ រស់នៅ ដោយសន្តិភាព ប្រជាធិបតេយ្យ សុខមាលភាព សេចក្តីថ្លៃថ្នូរ និងមានសមធម៌យេនឌ័រក្នុងសង្គម។

- **បេសកកម្ម៖**

អង្គការទ្រទ្រង់ស្ត្រីខ្មែរខេត្តកំពង់ធំ ធ្វើការជាមួយប្រជាពលរដ្ឋ ជាពិសេសស្ត្រីក្រីក្រ និង ជនងាយរងគ្រោះដើម្បីបង្កើនសមត្ថភាព និងលើកស្ទួយជីវភាពរស់នៅ របស់សហគមន៍ តាមរយៈកម្មវិធី ការរកប្រាក់ចំណូល កសិកម្ម អប់រំសុខភាពបឋម អភិបាលកិច្ចល្អ និងអភិរក្សធនធានជីវចំរុះ-បរិស្ថាន ដើម្បីឆ្លើយតបតម្រូវការជាមូលដ្ឋាន។

- **គោលដៅ:**

ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ និងមានសមត្ថភាពគ្រប់គ្រង ដឹកនាំ ចាត់ចែង គម្រោងអភិវឌ្ឍន៍ ក្នុងាហគមន៍ ដើម្បីធានាបាននូវ សន្តិសុខស្បៀង សុខមាលភាពដោយមានការចូលរួម។

# រចនាសម្ព័ន្ធ  អង្គការទ្រទ្រង់ស្ត្រីខ្មែរ( COWS )



# ផែនការយុទ្ធសាស្ត្ររបស់អង្គការ

គោលដៅយុទ្ធសាស្ត្របី សម្រាប់អង្គការគឺការអនុវត្តល្អ ស្មោះត្រង់ និងស្លូង់ជារ ដោយត្រូវធានាថា៖

- មានការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក ដើម្បីជួយដល់ការផ្តល់និងគាំទ្រកម្មវិធីដែលមានគុណភាពខ្ពស់។
- ពិនិត្យឡើងវិញ និងធ្វើឱ្យប្រសើរឡើងនៅពេលចាំបាច់នៃគោលនយោបាយ និងនីតិវិធី ជាពិសេសទាក់ទងនឹងការកើនឡើងនៃចំនួនតម្រូវការរបស់តំបន់គោលដៅសម្រាប់អង្គការ ។
- ដំណើរការដើម្បីទទួលបានការគាំទ្រថ្មីៗ ដូច្នេះហើយសុវត្ថិភាពហិរញ្ញវត្ថុរបស់អង្គការនឹងត្រូវបានកំពុងបន្ត។

# កម្មវិធីធំៗរបស់អង្គការទ្រទ្រង់ស្ត្រីខ្មែរ

- អង្គការមានកម្មវិធីចំនួន៣ធំគឺ៖

កម្មវិធីអភិបាលកិច្ច

កម្មវិធីសន្តិសុខស្បៀង/ធនធានធម្មជាតិ កម្មវិធីកសិកម្មនិងជលផល

កម្មវិធីសុខភាព

| មានគម្រោងចំនួនពអនុវត្តគឺ | គាំទ្រដោយ | រយៈពេល |
|---|---|---|
| ១)ពង្រឹងសិទ្ធិអំណាច សម្រាប់គណេយ្យភាពដំណាក់កាលទី២ នៅស្រុកសណ្តាន់ មាន២ឃុំគឺឃុំមានជ័យនិងឃុំងនភូមិចំនួន២០មានបុគ្គលិកអនុវត្តចំនួន២នាក់ស្រី | វិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (VBNK /BftW ) | 2021-2024 |
| ២) គម្រោងយើងរួមគ្នា (ឆ្ពោះទៅរកសមភាពយេនឌ័រដើម្បីអោយស្រ្តីនិងកុមារមានភាពរីករាយចំពោះសុខភាពនិងសិទ្ធពេញលេញ)។ | ADRA Cambodian | 2022-2026 |

# កិច្ចសហការការអនុវត្តគម្រោង និងក្រុមអ្នកទទួលផល

ខេត្ត

ស្រុក

ឃុំ

ភូមិ

ម្ចាស់ជំនួយ

ប្រជាពលរដ្ឋទូទៅ

អ្នកពាក់ព័ន្ធ

COWS

ក្រុមយុវជន,តំណាងសហគមន៍,ស្ត្រី

និងកុមារ និងជនជាតិដើមភាគតិច

# ១/គម្រោងពង្រឹងសិទ្ធិអំណាច សម្រាប់គណនេយ្យភាព

**គោលបំណង៖** ១)គោលការណ៍អភិបាលកិច្ចដែលរួមមានតម្លាភាព ការចូលរួមនិភាពអាចព្យាករណ៍បាន ត្រូវបានបញ្ចូលទៅក្នុងគ្រប់ទម្រង់នៅថ្នាក់មូលដ្ឋាន ក្នុងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត។

២)ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ ដើម្បីចូលរួមចំណែកឆ្ពោះទៅការអភិវឌ្ឍន៍យ៉ាងពេញលេញ តាមរយៈការរួមចំណែកទាក់ទងគណនេយ្យភាពជាមួយអ្នកជាប់ភារកិច្ច។

# កិច្ចសហការចូលរួមអនុវត្តគម្រោង



# លទ្ធផលចុះប្រមូលព័ត៌មានវាយតម្លៃគ្រាដើម

១) គម្រោងបានចុះប្រមូលទិន្នន័យក្នុង២ឃុំយក៤ភូមិគឺភូមិអូរត្នោត,វាលព្រីង,ផ្ទោលនិងភូមិពពឹងមានអ្នកចូលរួមសរុបចំនួន៤៧ន/ស្រី៤២ន។





# សកម្មភាពចុះតាមខ្នងផ្ទះ

៣/ចុះផ្សព្វផ្សាយតាមខ្នងផ្ទះស្តីពីការយល់ដឹងអំពីដំណើរការកសាងផែនការវិនិយោគឃុំ/សង្កាត់ មានអ្នកចូលរួមចំនួន៥១១នាក់/៣៩៤នាក់។





# សកម្មភាពប្រជុំពិគ្រោះយោបល់តាមភូមិ

៤/ ប្រជុំថ្នាក់ភូមិលើកទី១ស្តីពីការពិគ្រោះយោបល់ពីការកសាងកម្មវិធីវិនិយោគឃុំ/សង្កាត់ មានអ្នកចូលរួម( ៥៩០នាក់/៥៧៤នាក់ស្រី )។

៤.១/ ប្រជុំថ្នាក់ភូមិលើកទី២ស្តីពីការសម្រេចចិត្តនិងការទទួលខុសត្រូវមានអ្នកចូលរួមសរុបចំនួន( ៩៧១នាក់/ស្រី៨២៥នាក់ )។





# សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង

- CCs.CLs.CCWCs And Disetrict ចំនួន២៥នាក់/ស្រី២០នាក់មកពី ២០ភូមិក្នុងឃុំងននិងឃុំមានជ័យយល់ពីសកម្មភាពគម្រោងដែលត្រូវអនុវត្ត៣ឆ្នាំ(នៅសាលាស្រុកសណ្តាន់)។





# បញ្ហាដែលបានលើកដោយប្រជាពលរដ្ឋ និងការឆ្លើយតបរបស់អ្នកជាប់កិច្ច

- **ផែនការមូលដ្ឋានទាំង២ឃុំមាន៖**

-បង្គន់អានាម័យ,សាលាឆទាន,សាលាមត្តេយ្យ ,អណ្តូងដាក់លូ,ដាក់លូរំដោះទឹក,ជួសជុលផ្លូវគ្រួសក្រហម( ផ្លូវសំបុកមាន់ ),អំពើហឹង្សាក្នុងគ្រួសារ,បើកផ្លូវលំថ្មី,ធុងទឹកចំរោះ,ដាក់បង្គោលតភ្លើងតាមដងផ្លូវ,សំអាតបរិស្ថាន និងលំនៅដ្ឋាន។ល។

- *ការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋានតាមការសង្កេត និងការចូលរួមពីប្រជាពលរដ្ឋមានប្រមាណ៣០%នៃផែនការមូលដ្ឋាន(នេះគឺជាជោគជ័យនិងជាការយកចិត្តទុកដាក់ទទួលខុសត្រូវ)។*

# ២/ គម្រោងយើងរួមគ្នា

- គម្រោងយើងរួមគ្នា គាំទ្រដោយអាជ្រ៉ាកម្ពុជា មានរយៈពេល៥៧ខែ មានបុគ្គលិកអនុវត្តចំនួន៤នាក់/៣នាក់ស្រី។

**តំបន់គោលដៅ ៣ខេត្តគឺ៖**

១/ ខេត្តកំពង់ធំ ៦ឃុំ (ស្រុកសណ្ដាន់) ។

២/ខេត្តព្រះវិហារ ៧ស្រុក និង១ក្រុង ។

៣/ និងខេត្តស្ទឹងត្រែង ១៨ឃុំ (ស្រុកសេសាន្ត,ស្រុកសៀមបូកនិងស្រុកថាឡាបរិវ៉ាត់)។

# គម្រោងយើងរួមគ្នា

- សកម្មភាពក្នុងគម្រោង អង្គការទ្រទ្រង់ស្រ្តីខ្មែរ មានតួនាទី ចុះសិក្សាស្រាវជ្រាវ ពាក់ព័ន្ធ  SRHR and SGBV ។ ក្នុងនេះCOWSបាន

ចុះសម្ភាសន៍ប្រមូលទិន្នន័យសាកល្បងបានចំនួន១លើក ស្តីពីការរៀបការវ័យក្មេង និងការពរពោះវ័យក្មេង ដែលមានអ្នកចូលរួមចំនួន ( ៩០នាក់/៥៧នាក់ )ដោយប្រើវិធីសាស្រ្តចែកជា៣ក្រុមមានការសំភាសន៍ជា ( FGD , KII and HHs )ក្នុងឃុំចំនួន៣មានឃុំក្លែង,ឃុំងន,ឃុំមានជ័យ ក្នុងស្រុកសណ្តាន់។ និងបានរៀបចំរបាយការណ៍ស្រាវជ្រាវនេះធ្វើផែនការរកការគាំទ្រនិងអនុសាសន៍ល្អៗដើម្បីការអនុវត្តគម្រោងបន្តកាន់តែល្អប្រសើរ។

# លទ្ធផលទទួលបានពីការស្រាវជ្រាវ

- **ប្រធានបទ៖ ការរៀបការវ័យក្មេង និងការពរពោះវ័យក្មេងអាយុ១៥ឆ្នាំ-១៩ឆ្នាំ៖**

១.ក្មេងប្រុសចំនួន១៨នាក់/៣៣នាក់ស្មើ៥៥%ស្រីចំនួន២៩/៥៥នាក់ជឿថារៀបការឆាប់ជាការល្អ ហើយធ្វើឲ្យពួកគេឈប់រៀន ភាពក្រីក្រ ខ្វះចំណេះដឹងក្នុងការមើលថែគ្រួសារ ជំពាក់បំណុលគេ។

២.សមាជិកដែលមានឥទ្ធិពលមួយចំនួនក្នុងគ្រួសារគាំទ្រក្មេងស្រីឱ្យរៀបការ ព្រោះពួកគេឃើញភាគីម្ខាងមានទ្រព្យសម្បត្តិ ហើយនេះធ្វើឱ្យកូនរបស់ពួកគេឈប់រៀន។

៣.ក្មេងស្រីចំនួន២៤នាក់/៥៧នាក់ស្មើ៤២%កំពុងចូលរួមក្នុងការរួមភេទខណៈពេលដែលពួកគេពិតជាមិនដឹងពីរបៀបការពារខ្លួន ហើយនេះធ្វើឱ្យពួកគេទទួលបានការរំលោភបំពានផ្លូវភេទ ការបោះបង់ការសិក្សា ការអាម៉ាស់ការរៀបការដំបូង/មានផ្ទៃពោះ។ នេះក៏ប៉ះពាល់ដល់ជំនឿប្រពៃណីនៃតំបន់មួយចំនួនផងដែរ។

៤. បុរសចំនួន៦នាក់/៣៣នាក់ស្មើ១៨%ដាក់ខ្លួនឯងថាជាអ្នករកលុយ ហើយរឿងនេះធ្វើឱ្យពួកគេយកហេតុផលបង្ខំប្រពន្ធឱ្យរួមភេទ មានគូស្នេហ៍។

# លទ្ធផលទទួលបានពីការស្រាវជ្រាវ(ត)

៥. ស្ត្រីចំនួន៤នាក់/៥៧នាក់=៧%ត្រូវបានគេរាយការណ៍ថាបានទទួលការព្យាបាលមិនរាក់ទាក់ពីបុគ្គលិកថែទាំសុខភាព ហើយពួកគេមិនដឹងថាត្រូវធ្វើអ្វីនោះទេ គ្រាន់តែត្អូញត្អែរប្រាប់ប្តី និងម្តាយថាពួកគេមិនចង់ទៅថែទាំសុខភាពទៀតទេ ឬត្រូវបង្ខំខ្លួនឯងឱ្យទៅ។

៦. ស្ត្រីមួយចំនួន១១នាក់/៥៧នាក់=១៩%មិនហ៊ានប្រាប់ពីបញ្ហាផ្លូវភេទរបស់ពួកគេដល់អ្នកដទៃ ហើយបន្ទាប់មកពួកគេមិនអាចទទួលបានការថែទាំសុខភាពពេញលេញទាក់ទងនឹងសុខភាពផ្លូវភេទនោះទេ។

៧. បុរសចំនួន២៣នាក់/៣៣នាក់=៧០%ដឹងអំពីផែនការគ្រួសារពីប្រព័ន្ធផ្សព្វផ្សាយសង្គម (Facebook........)ដឹងពីហានិភ័យនៃការសម្រាលកូន ប៉ុន្តែពួកគេនៅតែជឿថាការរៀបការនៅវ័យក្មេងគឺជាចំណុចល្អសម្រាប់មនុស្សពេញវ័យ និងចង់មានកូននៅវ័យក្មេង។

# លទ្ធផលទទួលបានពីការស្រាវជ្រាវ(ត)

៨.បុរស១៤នាក់/៣៣នាក់=៤២%បានលើកថាការរៀបការទាន់ពេលដោយសារពួកគេជឿថាជាមនុស្សពេញវ័យហើយចេះស្រឡាញ់ក្មេងស្រីដែលពួកគេស្រឡាញ់ និងខ្លាចអ្នកដទៃរៀបការជាមួយក្មេងស្រីរបស់ពួកគេ។នេះធ្វើឱ្យពួកគេឈប់រៀន។

៩.បុរសចំនួន១២នាក់/៣៣នាក់=៣៦%ជឿថាពួកគេមិនអាចបន្តការសិក្សាបានទេ ដោយសារតែពួកគេក្រីក្រ ការគិតមិនល្អក្នុងការសិក្សាចេះស្រលាញ់ស្រី និងខ្លាចអ្នកដទៃរៀបការជាមួយស្រីមុនពួកគេ។



# ការប្រើប្រាស់លទ្ធផលស្រាវជ្រាវប្រជុំ ( Pro.TWGH )

ក្រុមការងារបានរៀបចំកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធចំនួន៣លើក៖

១/ការបង្ហាញលទ្ធផលស្រាវជ្រាវអំពី« ស្ត្រីរៀបការវ័យក្មេងនិងស្ត្រីពរពោះវ័យក្មេង »

ក្នុងកិច្ចប្រជុំនៅ ( Pro.TWGH ) (អ្នកពាក់ព័ន្ធចូលរួមចំនួន២៦នាក់/ស្រី៨នាក់ )។





# ការប្រើប្រាស់លទ្ធផលស្រាវជ្រាវក្នុងកិច្ចប្រជុំនានា

ការបង្ហាញលទ្ធផលស្រាវជ្រាវអំពី« ស្ត្រីរៀបការវ័យក្មេងនិងស្ត្រីពរពោះវ័យក្មេង » ភ្ជាប់កម្មវិធីទិវាសិទ្ធិនារីអន្តរជាតិ៨មីនាលើកទី១១២ក្រោមប្រធានបទ«បញ្ឈប់អំពើហឹង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធឌីជីថល»( អ្នកពាក់ព័ន្ធចូលរួមចំនួន២៦៥នាក់ /ស្រី១៧៣នាក់ )។





# ការប្រើប្រាស់លទ្ធផលស្រាវជ្រាវប្រជុំជាមួយPCC

ការបង្ហាញលទ្ធផលស្រាវជ្រាវអំពី« ស្ត្រីរៀបការវ័យក្មេងនិងស្ត្រីពរពោះវ័យក្មេង » នៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសទី ៣នៃគណៈកម្មការគ្រប់គ្រងគម្រោងទាំង ៣ខេត្ត ព្រះវិហារ កំពង់ធំ និង ស្ទឹងត្រែង PCC at OD KPT អ្នកចូលរួមចំនួន ( ១១នាក់/ស្រី៥នាក់ )។



| បញ្ហាប្រឈម | ដំណោះស្រាយ |
| --- | --- |
| ❑ បញ្ហាដែលលើកឡើងដោយប្រជាពលរដ្ឋភាគច្រើនការជួសជុលផ្លូវលំតាមភូមិ។ | ការឆ្លើយតបរបស់អាជ្ញាធរបានបន្សីចូលក្នុងផែនការវិនិយោគឃុំស្វែងរកការគាំទ្រ។ |
| ❑ តាមសហគមន៍ពាក់ព័ន្ធមានអំពើហឹង្សាក្នុងគ្រួសារ។ | ឃុំនិងគ.ក.ន.កនិងអាជ្ញាធរភូមិសហការគ្នាមានផែនការចុះផ្សព្វតាមភូមិផ្សាយដល់ប្រជាពលរដ្ឋទូទៅតាមភូមិ។ |
| ការដាក់ឯកសារទៅគណកម្មការជាតិក្រមសីលធម៌វិជ្ជាជីវៈ ពាក់ព័ន្ធការចុះស្រាវជ្រាវមានការយឺតយ៉ាវ។ | នាយិកាព្យាយាមទំនាក់ទំនងជាមួយគណកម្មការជាតិក្រមសីលធម៌វិជ្ជាជីវៈប្រចាំ។ មូលហេតុគណកម្មការប្រជុំ២ខែម្តង។ |
| | |

# ចំនុចរៀនសូត្រ

- ការបង្ហាញលទ្ធផលស្រាវជ្រាវលើកទី១ដល់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំឃើញថាឃុំមានចំណាប់អារម្មណ៍ច្រើនរាល់បញ្ហាដែលCOWSបានបង្ហាញគឺមានពិតៗ នៅថ្នាក់មូលដ្ឋាន។អាជ្ញាធរមូលដ្ឋានស្រុក/ឃុំ/ភូមិCMC និងមានផែនការចុះបញ្ជ្រាប/ផ្សព្វផ្សាយប្រធានបទដែលពាក់ព័ន្ធទៅប្រជាពលរដ្ឋទូទៅក្នុងសហគមន៍។
- នៅតាមសាលារៀនលោកគ្រូអ្នកគ្រូចាប់អារម្មណ៍ទៅលើអវត្តមានសិស្សានុសិស្ស និងទិន្នន័យសិស្សបោះបង់ការសិក្សាដែលភាគច្រើនក្នុងកំរិតអនុវិទ្យាល័យ លោកគ្រូនាយកនិងលើកប្រធានបទសិស្សបោះបង់ការសិក្សា មានដៃគូវ័យក្មេង លើកជាផែនការដាក់ម៉ោងបញ្ជ្រាបតាមសប្តាហ៍និមួយៗដល់សិស្សតាមថ្នាក់។អាណាព្យាបាល/មាតាបិតាទៅចូលរួមការផ្សព្វផ្សាយជាមួយផែនការនានាក្នុងឃុំ ធ្វើអោយសហគមន៍មានការផ្លាសប្តូរឥរិយាបទនាពេលបន្ទាប់ៗបាន។

# ការសន្និដ្ឋាន

- គម្រោងទាំងអស់ដែល អនុវត្តទទួលបានជោគជ័យ ក៏អាស្រ័យដោយមានការសហការល្អ ផ្តល់ឱកាស និងការចូលរួមយ៉ាងសកម្មពីអាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធជាមួយបុគ្គលិកអង្គការផ្ទាល់យ៉ាងជិតស្និត។សំខាន់គឺមានតម្លាភាព មានការចូលរួមមានគណនេយ្យភាព និងទំនុកចិត្តជំនឿពីក្រុមគោលដៅ ប្រជាពលរដ្ឋយល់ដឹងចូលរួមយ៉ាងសកម្ម។ពិសេសសំខាន់ទៅទៀតក៏ដោយមានការគាំទ្រជាថវិកា ជំនាញ ចំណេះដឹងជាច្រើន ពីគ្រប់ម្ចាស់ជំនួយជាដៃគូផងដែរ។




អរគុណ

លោក លោកស្រី នូវចំណាប់អារម្មណ៍